## រាជបណ្ឌិត្យសភាកម្ពុជា
## វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ
## ផ្នែកសិល្បៈនិងឥស្សរិយយស

អត្ថបទស្រាវជ្រាវស្តីពី

# គ្រឿងតុបតែងលម្អតួសម្តែងនៅក្នុងល្ខោនបាសាក់ខ្មែរ










ស្រាវជ្រាវដោយ ៖ លោកស្រី សរ សិលា
លោកស្រី យ៉ាន់ វិតារតន៍

ខែមីនា ឆ្នាំ២០២០

## ១- សេចក្ដីផ្ដើម

ប្រទេសកម្ពុជា ជាប្រទេសមួយដែលត្រូវបានគេទទួលស្គាល់ថាមានវប្បធម៌និងអរិយធម៌ដ៏ខ្ពង់ខ្ពស់ និងសម្បូរបែបមួយនៅក្នុងពិភពលោក។ ភាពខ្ពង់ខ្ពស់និងសម្បូរបែបខាងវប្បធម៌នេះ បានផ្សព្វផ្សាយទៅពាសពេញពិភពលោកតាមរយៈសិល្បៈនិងទស្សនីយភាពសម្ដែងនានា របាំបុរាណ របាំប្រពៃណី ល្ខោនផ្សេងៗ ដូចជា ល្ខោនស្រមោល ល្ខោនស្បែក ល្ខោនបិទមុខ ល្ខោនខោល ល្ខោនយីកេ ល្ខោនបាសាក់ ជាដើម ដែលសុទ្ធបង្ហាញទំនៀមទម្លាប់ ប្រពៃណី អត្តសញ្ញាណ និងភាពឧត្តុង្គឧត្តមនៃវប្បធម៌ អរិយធម៌ខ្មែរតាំងពីបុរាណកាលរៀងមក។

តាមការសិក្សាស្វែងយល់កន្លងមក ល្ខោនបាសាក់ គឺជាល្ខោនមួយបែបដែលមានការពេញនិយមជាងគេនៅក្នុងស្រទាប់មហាជនខ្មែរកំឡុងឆ្នាំ១៩៨០និង១៩៩០។ ប៉ុន្តែនាសម័យក្រោយមក ជាពិសេសសម័យបច្ចុប្បន្នតែម្ដង ល្ខោនបាសាក់គឺហាក់ដូចជាពុំមានអត្ថិភាពនៅក្នុងប្រជាជនខ្មែរឡើយ ជាពិសេសយុវវ័យ ពោលគឺពួកគេពុំស្គាល់សោះថា ល្ខោនបាសាក់ជាអ្វី វាមានទម្រង់យ៉ាងដូចម្ដេច ល្ខោននេះមានការតុបតែងឬប្រើប្រាស់សម្ភារៈបែបណានៅពេលសម្ដែង ហើយពួកគេរឹតតែមិនដឹងទៀតថាតើល្ខោនបាសាក់នេះមានប្រភពមកពីណានោះទេ។

ដូច្នេះ ខាងក្រោមនេះយើងនឹងធ្វើការសិក្សាស្វែងយល់ពីប្រភពនៃល្ខោនបាសាក់និងគ្រឿងតុបតែងលម្អសំខាន់ៗដែលគេប្រើប្រាស់សម្រាប់តុបតែងលម្អតួសម្ដែងទាំងពីរភេទនៅពេលសម្ដែង។

## ២- ដើមកំណើតល្ខោនបាសាក់ក្នុងប្រទេសកម្ពុជា

ពេលណានិយាយទៅដល់ល្ខោនបាសាក់ ប្រជាជនខ្មែរនឹកឃើញដំបូងបំផុតទៅដល់ឈ្មោះទន្លេមួយដ៏ធំរបស់ប្រទេសកម្ពុជាយើង គឺទន្លេបាសាក់។ ទន្លេបាសាក់ ជាខ្នែងមួយក្នុងចំណោមខ្នែងទាំងបួននៃទន្លេមេគង្គដែលប្រសព្វគ្នានៅភ្នំពេញ។ ចំណុចប្រសព្វគ្នានេះគេហៅថា ***ចតុមុខឬទន្លេបួនមុខ។***

ទាក់ទងទៅនឹងដើមកំណើតឬវត្តមានល្ខោនបាសាក់នៅលើទឹកដីកម្ពុជា គឺមានការលើកឡើងខុសៗគ្នា៖

- ឯកសាររបស់លោក យឹង ហុកឌី ល្ខោនបាសាក់បានចូលមកក្នុងប្រទេសកម្ពុជា គឺនៅក្នុងទសវត្សឆ្នាំ១៩២០។[1]
- ឯកសាររបស់លោកតា ឆេង ផុន បានបង្ហាញថា ល្ខោនបាសាក់បានចូលមកប្រទេសកម្ពុជា ប្រហែលជានៅឆ្នាំ១៩៣០ ប៉ុន្តែ នៅពេលនោះមធ្យោបាយនៃការសម្ដែងល្ខោនបាសាក់

[1] យឹង ហុកឌី : ***ស្នើកម្មអក្សរសិល្ប៍ចិនលើកម្ពុជានាសតវត្សទី១៩ និងទី២០,*** បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៨, ទំព័រ៨

ចម្រៀង តន្ត្រី សម្លៀកបំពាក់នៅតែមានពណ៌សម្បុរចម្រុះ។ រីឯពណ៌សម្បុរជាតិខ្មែរ គឺមានប្រហែល៧០ភាគរយប៉ុណ្ណោះ។[2]

- ប្រភពខ្លះបញ្ជាក់ថា ល្ខោនបាសាក់ខ្មែរ គឺទទួលឥទ្ធិពលមកពីល្ខោនអូប៉េរ៉ារបស់ចិន និង ល្ខោនកៃលឿងរបស់វៀតណាម និងត្រូវបានខ្មែរយើងធ្វើឱ្យមានលក្ខណៈជាល្ខោនបាសាក់ខ្មែរនៅទសវត្សឆ្នាំ១៩៦០ ។[3]
- លោក កង ចន្ទីរិទ្ធ ប្រធានការិយាល័យសិល្បៈ និងទស្សនីយភាពខេត្តកំពង់ចាមបាន បញ្ជាក់ថា ល្ខោនបាសាក់ខ្មែរ គឺតួឯកប្រុសមានការតុបតែងដូចគ្នាបេះបិទទៅនឹងល្ខោនហ៊ី របស់ចិន ហើយសូម្បីតែចម្រៀងនិងឧបករណ៍តន្ត្រីនៅក្នុងបាសាក់ខ្មែរយើងមួយចំនួនក៏ ចម្លងពីចម្រៀងនិងឧបករណ៍តន្ត្រីរបស់ល្ខោនហ៊ីចិនដែរ។ ដូច្នេះ បើនិយាយថាល្ខោន បាសាក់ខ្មែរមានប្រភពពីល្ខោនហ៊ីចិន គឺវាមានលក្ខណៈត្រឹមត្រូវជាងការដែលថាមាន ប្រភពមកពីល្ខោនកៃលឿងរបស់វៀតណាម។[4]
- បើតាមឯកសាររបស់គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ឆ្នាំ២០០៣បង្ហាញថា ល្ខោន បាសាក់ដែលយើងស្គាល់សព្វថ្ងៃមានប្រភពពីល្ខោនទ្រើងឃ្លោក ហើយបានរីកចម្រើន ដោយស្នាដៃបញ្ញវន្តមួយក្រុមដែលមានចំណេះដឹងជ្រៅជ្រះខាងអក្សរសិល្ប៍ និងសាសនា ក្រោមការដឹកនាំរបស់ចៅអធិការវត្តខ្សាច់កណ្តាល ***បាសាក់ព្រះត្រពាំង*** កម្ពុជាក្រោម ឈ្មោះ លោកគ្រូ សួរ។ ចំពោះរឿងរ៉ាវដែលទាក់ទងនឹងល្ខោនទ្រើងឃ្លោក គឺថាក្រោយពេលសឹកពី ព្រះសង្ឃមកដោយមានគំនិតចង់ថែរក្សាលើកតម្លៃវប្បធម៌ខ្មែរ លោកគ្រូ សួរ ក៏បានប្រមែ ប្រមូលអ្នកសឹកពីបួស បណ្ឌិត ព្រមដោយកូនសិស្ស សិស្សគណ ពុទ្ធបរិស័ទផ្សេងៗទៀត បង្កើតជាវង់ល្ខោនមួយ។ កាលនោះដោយសារមានកង្វះខាតខាងផ្នែកសម្ភារៈនិងឆាក ល្ខោន គឺគេនាំគ្នាសម្តែងដោយផ្ទាល់ដីក្នុងរោងដែលសង់ឡើងដោយប្រក់ ឬកាប់មែកឈើ យកមកគ្រប ដែលស្រដៀងគ្នានឹងទ្រើងដាំឃ្លោក ទើបអ្នកស្រុកនាំគ្នានិយមហៅល្ខោននេះ ថា *ល្ខោនទ្រើងឃ្លោក។* ល្ខោនទ្រើងឃ្លោកមានវត្តមានរហូតដល់អំឡុងឆ្នាំ១៩៥៣ ឬក៏ ក្រោយនោះបន្តិចផងនៅជាយក្រុងភ្នំពេញនិងជនបទនានា។[5] មានអ្នកខ្លះនិយមហៅ

---

[2] សំរាំង កំសាន្ត, អ៊ុន ទឹម, ស៊ីក ប៊ុនហុក : ***គោលទស្សនៈធំៗចំពោះវប្បធម៌ខ្មែរ និងការអភិវឌ្ឍ***, មជ្ឈមណ្ឌលវប្បធម៌ និង វិបស្សនា, ២០០០, ទំព័រ២

[3] www.khmerguide.com, Lakhaon Bassac ( Bassac Theatre )

[4] កង ចន្ទីរិទ្ធិ : ការសម្ភាសអំពី«កំណើតល្ខោនបាសាក់នៅកម្ពុជា», មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាម, ថ្ងៃទី១៤ ខែតុលា ២០១១

[5] គណៈកម្មការស្រាវជ្រាវសិល្បៈវប្បធម៌ ទស្សនីយភាពខ្មែរ, រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ២០០៣, ទំព័រ១៥៤

ល្ខោនទ្រើងឃ្លោកថា ***យូរកេរ្តិ៍*** វិញ ព្រោះពាក្យយូរកេរ្តិ៍នេះជាពាក្យមានតម្លៃសម្រាប់បញ្ជាក់ទម្រង់សិល្បៈនេះ ហើយជាមរតកដ៏យូរលង់មកហើយរបស់ជនជាតិខ្មែរយើង។ ទន្ទឹមនឹងនោះ ឈ្មោះនេះត្រូវបានបងប្អូនខ្មែរកម្ពុជាក្រោមប្រើប្រាស់រហូតមកដល់សព្វថ្ងៃសម្រាប់សម្គាល់ទម្រង់ល្ខោនមួយដែលខ្មែរយើងនិយមហៅគឺល្ខោនបាសាក់។

ក្រៅពីប្រភពខាងលើ ក៏នៅមានប្រភពផ្សេងៗទៀតដែលនិយាយពីប្រវត្តិរបស់បាសាក់នៅកម្ពុជាដែរ។

## ៣- គ្រឿងតុបតែងលម្អតួសម្តែងនៅក្នុងល្ខោនបាសាក់

បើតាមការរៀបរាប់ពីប្រភពល្ខោនបាសាក់យើងឃើញថា ល្ខោនបាសាក់ខ្មែរយើង គឺមានការចម្លងចេញពីល្ខោនហ៊ីរបស់ចិនឬវៀតណាម ហេតុនេះទើបគេឃើញការតុបតែងតួសម្តែង ជាពិសេសតួប្រុស គឺមានលក្ខណៈដូចគ្នាស្ទើរតែទាំងស្រុងជាមួយតួសម្តែងប្រុសនៅក្នុងល្ខោនហ៊ី។ ដោយឡែកតួស្រីពីមុនគឺមានការតុបតែងបែបល្ខោនហ៊ីចិនខ្លះ តែដល់សម័យក្រោយមកមានការកែច្នៃឱ្យតួនាងស្លៀកពាក់ និងតុបតែងគ្រឿងលម្អបែបខ្មែរបុរាណយើងវិញ។ តាមលោក ប្រាក់ ប៊ិន ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈខេត្តតាកែវបញ្ជាក់ថា មូលហេតុដែលតួស្រីមានការកែច្នៃបែបនេះ ពីព្រោះប្រទេសកម្ពុជាយើងគឺជាប្រទេសដែលមានវប្បធម៌និងអរិយធម៌ដ៏ខ្ពង់ខ្ពស់តាំងពីសម័យបុរាណមក ហើយស្ត្រីខ្មែរគឺជាតួអង្គយ៉ាងសំខាន់ក្នុងការថែរក្សា លើកស្ទួយប្រពៃណីនិងវប្បធម៌របស់ជាតិ ព្រមទាំងមានចិត្តនឹងនរ បរិសុទ្ធ ស្មោះត្រង់មិនងាយកែប្រែ។ ចំណែកតួប្រុស គឺមានការកែប្រែ ដូច្នេះងាយចម្លងវប្បធម៌របស់ប្រទេសដទៃ។[6]

លោកបានបន្ថែមថា ការដែលតួនាង(តួឯកស្រី)លែងតុបតែងគ្រឿងលម្អតាមតួឯកស្រីនៅក្នុងល្ខោនហ៊ីចិននេះ មិនមែនមានន័យថាតួនាងល្ខោនបាសាក់ខ្មែរមិនចម្លងម៉ូតសម្លៀកបំពាក់ ឬគ្រឿងតុបតែងកាយពីសិល្បៈនៃប្រទេសដទៃទេ គឺជួនកាលតួទាំងពីរ(ប្រុសនិងស្រី)បានចម្លងម៉ូតសម្លៀកបំពាក់និងគ្រឿងតុបតែងពីតារាភាពយន្ត និងសិល្បៈប្រទេសផ្សេងដែរ ជាពិសេសតាមតារាភាពយន្តឥណ្ឌាក្នុងអំឡុងទសវត្សរ៍៨០និង៩០។ ប៉ុន្តែការចម្លងនេះ មិនមែនគ្រប់ក្រុមល្ខោនទាំងអស់ទេ។

[6] ប្រាក់ ប៊ិន : ការសម្ភាសន៍អំពី«គ្រឿងតុបតែងតួសម្តែងនៅក្នុងល្ខោនបាសាក់ខ្មែរ», មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ, ថ្ងៃទី០៤ ខែតុលា ២០១១

នៅក្នុងការសម្ដែងល្ខោនបាសាក់ ការតុបតែងលម្អនៅលើរាងកាយរបស់តួសម្ដែង គឺជារឿងសំខាន់។ គ្រឿងលម្អដូចជាជាសម្លៀកកបំពាក់ គ្រឿងអលង្ការ(ខ្សែដៃឬកងដៃ កងជើង ខ្សែក) ត្រូវតែរចនាឱ្យប្លែកដើម្បីមានភាពទាក់ទាញ។ ក្នុងចំណោមគ្រឿងតុបតែងលម្អទាំងអស់ គ្រឿងលម្អដែលសំខាន់មិនអាចខ្វះបាន គឺក្បាំង ស្វ៉ែង មកុដ ប៉ានដៃ និងណា(ដែលរុំព័ទ្ធចង្កេះហើយទម្លាក់ចំពីមុខខោចុះមកក្រោម)ជាដើម។



តួឯកល្ខោនបាសាក់ពេលតុបតែងគ្រឿលម្អ
សម្រាប់ការសំដែង

គ្រឿងតុបតែងលម្អដូចជាក្បាំង មកុដ ស្វ៉ែង ប៉ាន់ដៃ និងណានេះមានចម្ងល់ខ្លះបានចោទឡើងថា តើហេតុអ្វីបានជានៅក្នុងការសម្ដែងល្ខោនបាសាក់តួអង្គចាំបាច់ពាក់នូវគ្រឿងទាំងនោះ តើវាមានអត្ថន័យនិងប្រភពមកពីណា? មានប៉ុន្មានប្រភេទ មានក្បាច់អ្វីខ្លះ? តើវាមានភាពខុសគ្នាដូចម្ដេចខ្លះសម្រាប់គ្រឿងលម្អរបស់តួអង្គមួយទៅតួអង្គមួយ? ហើយគ្រឿងទាំងនោះផលិតមកពីអ្វី និងមានការវិវត្តយ៉ាងដូចម្ដេច?

## ក- ក្បាំង

តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ក្បាំង គឺមានន័យថា របាំងមុខ។

នៅក្នុងល្ខោនបាសាក់ ក្បាំង គឺសំដៅទៅលើគ្រឿងតុបតែងលម្អមួយប្រភេទដែលតួអង្គសម្ដែងយកមកពាក់ពីលើក្បាលដោយដាក់វាឱ្យរាងគ្របបន្តិចលើថ្ងាស។ ក្បាំងល្ខោនបាសាក់មាន៣ប្រភេទ គឺក្បាំងសម្រាប់តួឯកប្រុស ក្បាំងសម្រាប់តួឯកស្រី ឬគេហៅម្យ៉ាងទៀតថាតួនាង និងក្បាំងតួយក្ស។

តាមលោក សោម ម៉ាកលី ជាតួឯក និងជាគ្រូបង្ហាត់សិល្បៈល្ខោនបាសាក់នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តកំពង់ចាមបានឱ្យដឹងថា ក្បាំងតួប្រុស គឺមានទម្រង់ដូចគ្នាបេះបិទទៅនឹងក្បាំងរបស់តួល្ខោនហ៊ីចិន ដែលធ្វើពីក្រណាត់ ដេរជាមួយសសៃអំបោះ ដោយនៅខាងក្នុងគេយកក្រដាសដែលរឹង ឬហ្វីលថតធំៗមកដាក់ដើម្បីធ្វើឱ្យក្បាំងនោះរឹងអាចបញ្ឈរបាន ហើយមានច្រើនជាន់ដើម្បីបង្ហាញពីអំណាចរបស់តួថែមទាំងមានធ្វើបថ្ងាំង (គឺជាផ្ទាំងកញ្ចក់តូចៗដែលគេដាក់រឹស័ដេរភ្ជាប់ជាមួយក្បាំងសម្រាប់ពេលតួប្រុសលោតឬវាយប្រយុទ្ធឃើញបន្លឺចាំង និងមានសោភ័ណភាព) ភ្ជាប់ជាមួយ។

ក្បាំងមានប៉ាក់ដោយឱនចម្រុះពណ៌ មានរចនានូវក្បាច់ផ្សេងៗតាមចំណង់ចំណូលចិត្ត និងមានច្រើនជាន់។ ការធ្វើក្បាំងនេះ គឺគេធ្វើឱ្យសមតម្រូវទៅតាមមុខរបស់តួ បើតួមុខរាងតូច គឺគេធ្វើក្បាំងឱ្យរាងធំបន្តិច តែបើតួមុខរាងធំ គឺគេធ្វើក្បាំងឱ្យរាងតូចបន្តិចវិញ ហើយមុននឹងពាក់ក្បាំងគឺគេត្រូវយកក្រណាត់១ផ្ទាំងមករុំជុំវិញថ្ងាសព័ទ្ធទៅក្រោយ និងមួយផ្ទាំងទៀតគ្របកុំឱ្យឃើញសក់ និងទំលាក់ចុងក្រណាត់ទៅខាង

ក្រោយដែរ បន្ទាប់មកគេយកផ្កា៣ឬ៤ ដែលធ្វើពីក្រណាត់ហើយមានរាងធំបន្តិចមកដាក់បាំងពីក្រោយក្បាំងដើម្បីកុំឱ្យឃើញស្នាមថ្នេរ និងស្នាមឱនរបស់ក្បាំង។

ក្បាំងតួយក្ស គឺមានរាងស្រដៀងនឹងក្បាំងតួឯកប្រុសដែរ គ្រាន់ក្បាំងយក្សគឺគេធ្វើឱ្យធំៗជាងមុខខ្លាំង ដើម្បីបង្ហាញពីភាពកាចសាហាវ ឃោរឃៅរបស់យក្ស។

រីឯក្បាំងរបស់តួនាង(តួឯកស្រី) ពីមុនពេលដែលខ្មែរយើងទើបចម្លងល្ខោនបាសាក់នេះមក គឺក្បាំងតួនាងមានទម្រង់ប្រហាក់ប្រហែលទៅនឹងក្បាំងបុរសដែរ លុះក្រោយមកក៏វិវត្តដោយចម្លងតាមទម្រង់និងក្បាច់រចនាផ្សេងៗដែលមាននៅក្នុងសិល្បៈរបស់ខ្មែរតាំងតែពីសម័យដើមមក។ ក្បាំងសម្រាប់តួស្រីឥឡូវនេះ គឺធ្វើពីដែក ស្ពាន់ ឬលង្ហិនមានបាញ់នូវពណ៌ទឹកមាស និងលម្អដោយក្បូរក្បាច់រចនាផ្សេងៗដែលជួនកាលមានមួយជាន់ បីជាន់ ប្រាំជាន់ ប្រាំពីរជាន់ និងដប់មួយជាន់ ដែលជាន់នីមួយៗគឺមានអត្ថន័យរបស់វាដោយឡែកៗពីគ្នា។

នៅក្នុងសិល្បៈល្ខោនបាសាក់ ក្បាំងតួនាងនេះ គឺត្រូវបានគេចាត់ទុកថា ជាវត្ថុដែលខ្ពស់និងជាគ្រឿងសក្ការៈដែលត្រូវតែតម្កល់នៅលើទីខ្ពស់មិនអាចដាក់ផ្ទាល់លើដី ឬទីកន្លែងដែលគគ្រិចបានឡើយ ហើយគេត្រូវពាក់វាចុងក្រោយបង្អស់ ដោយមុននឹងលើកយកមកពាក់ គឺត្រូវធ្វើនូវពិធីសក្ការៈសែនព្រេនសុំការអនុញ្ញាតជាមុនសិន ធ្វើយ៉ាងនេះទើបពេលសម្តែង តួមិនមានអារម្មណ៍ភ័យខ្លាច ឬបាក់ស្មារតី បើមិនធ្វើដូច្នេះទេ គឺតួមិនអាចសម្តែងបានល្អឡើយ ហើយជួនកាលឈឺទៀតក៏មាន។



ក្បាំងតួប្រុស



ក្បាំងតួនាងសម័យបច្ចុប្បន្ន



ក្បាំងមួយប្រភេទទៀតរបស់តួប្រុស

### ខ- ស្វ៉ែងក

តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ស្វ៉ែង គឺប្រើចំពោះតែរាជសព្ទ ដែលមានន័យថា ក នៃព្រះមហាក្សត្រ។

នៅក្នុងល្ខោនបាសាក់ ស្វ៉ែងក គឺសំដៅទៅលើគ្រឿងតុបតែងដែលគេប្រើសម្រាប់ពាក់រុំជុំវិញករបស់តួឯកទាំងតួប្រុស តួយក្ស និងតួនាង។

នៅក្នុងល្ខោនបាសាក់ ស្វ៉ែងកសម្រាប់តួប្រុសនិងតួនាង គេនិយមយកពណ៌ស្រស់ មានលក្ខណៈច្បាស់ៗ ដើម្បីឱ្យប៉ាក់ឌិនឃើញលេចស្អាត។ រីឯស្វ៉ែងរបស់តួយក្ស គឺគេច្រើនយកពណ៌រាងងងឹត ដើម្បីបង្ហាញពីភាពអាក្រក់ចិត្តខ្មៅ។

ចំពោះការធ្វើស្វ៉ែងកនេះ គេមិនកាត់ស្វ៉ែងឱ្យតូចភ្ជាប់ជិតកពេកនោះទេ គឺកាត់ឱ្យមានរាងធ្លាក់ចុះបន្តិចដើម្បីឱ្យលេចចេញសាច់កញ្ចឹងកដោយយកផ្នែកកណ្ដាលរាងធំ ហើយដេប៉ាក់ឌិនចម្រុះពណ៌ អមដោយម៉ូត និងក្បាច់ផ្សេងៗ ប៉ុន្តែក្បាច់ដែលគេនិយមជាងគេ គឺក្បាច់ផ្កាច័ន្ទ ភ្ញីទេស ភ្ញីភ្លើង និងក្បាច់ក្រពុំឈូកជាដើម។



ស្វ៉ែងកតួនាងដែលចម្លងម៉ូតតាមបែបខ្មែរ



ស្វ៉ែងកតួប្រុសប៉ាក់ក្បាច់ភ្ញីទេសមាន
រាងស្រទាប់ផ្កាឈូក



ស្វ៉ែងកតួប្រុសប៉ាក់ក្បាច់ផ្កាច័ន្ទកណ្ដាលមានរាងមូល

បើតាមលោក គយ សារ៉ុម ប្រធានការិយាល័យសិល្បៈទស្សនីយភាពនៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ បានមានប្រសាសន៍ថា នៅសម័យមុនស្ទូវែងកនេះ គឺគេធ្វើពីក្រណាត់ញាត់គស្លើងៗនៅខាងក្នុង ហើយមានប៉ាក់ដោយអង្កាំដែលភាគច្រើនគេនិយមប៉ាក់ក្បាច់ភ្នែកមាន់តែមួយម៉ូតគត់។ ប៉ុន្តែសម័យបច្ចុប្បន្ន គេប្រើឱនចម្រុះពណ៌មកប៉ាក់ជំនួសវិញ តែបើក្រុមល្ខោនណាមានធនធានច្រើន តួនាងគេប្រើស្ទូវែងកដែលធ្វើពីដែកឬលង្ហិនបាញ់រំលេចដោយពណ៌ទឹកមាស និងមានក្បូរក្បាច់រចនាផ្សេងៗ។ ការដែលគេបាញ់ពណ៌ទឹកមាសនេះ គឺដោយសារចង់រំលេចឱ្យចេញនូវពណ៌មាសដូចជាមកុដរបស់ព្រះមហាក្សត្រ ឬព្រះមហាក្សត្រិយ៍។[7]

## គ- ប៉ានដៃ

តាមវចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត ទំព័រ៦២៦ បានពន្យល់ថា ប៉ាន គឺមានន័យថា ពាសពីលើ ស្រោបថែម ដាក់ ឬពាក់ ។ ប៉ាន ជានាមមានន័យថា ប្រដាប់គ្រប សម្រាប់ប៉ះភ្ជាប់។ ដូច្នេះប៉ានដៃ មានន័យថា ប្រដាប់សម្រាប់ពាក់ ឬប្រដាប់សម្រាប់ពាសលើដៃ។

នៅក្នុងល្ខោនបាសាក់ ប៉ានដៃ(គេអាចហៅផាប់ដៃក៏បាន) គឺជាគ្រឿងលម្អម្យ៉ាងដែលគេយកមកពាក់នៅលើដើមដៃទាំងសម្រាប់តួឯកប្រុស និងសម្រាប់តួស្រី។ ប៉ានដៃឬផាប់ដៃនេះ ក៏មិនខុសគ្នាពីក្បាំង និងស្ទូវែងកដែរ គឺពីមុនពេលដែលល្ខោនបាសាក់ទើបចូលមកដល់ប្រទេសកម្ពុជា ប៉ានដៃឬផាប់ដៃនេះគេធ្វើពីក្រណាត់ ប៉ាក់ឱន និងមានញាត់គឬសំឡីនៅខាងក្នុង តែសម័យបច្ចុប្បន្នដោយសារបច្ចេកទេសមានការរីកចម្រើន និងមានធនធានសម្បូរបែប ប៉ាន់ដៃឬផាប់ដៃនេះគេធ្វើពីដែក ស្ពាន់ ឬលង្ហិនជំនួសវិញ ដោយមានឆ្លាក់ជាក្បូរក្បាច់រចនាផ្សេងៗ។ ប៉ានដៃឬផាប់ដៃតួនាងមានទម្រង់ជាកងដែលមានរាងកណ្ដាលធំឆ្លាក់ធ្វើជាក្បាច់កញ្ចុំផ្កា ឯខាងក្រោយមានទំហំតូចល្មម រីឯប៉ាន់ដៃឬផាប់ដៃតួប្រុសមានរាងធំហើយវែងជាង។



ផាប់ដៃតួប្រុសមើលពីមុខ និងមើលពីចំហៀង

---

[7] គយ សារ៉ុម : ការសម្ភាសអំពី«គ្រឿងលម្អតួនៅក្នុងល្ខោនបាសាក់ខ្មែរ», មន្ទីរវប្បធម៌ និងវិចិតករសិល្បៈខេត្តតាកែវ, ថ្ងៃទី០៤ ខែតុលា ២០១១



ប៉ាន់ដៃ ឫផាប់ដៃតួនាងសម័យ

សម័យបច្ចុប្បន្ននេះ ប៉ាន់ដៃឫផាប់ដៃរបស់តួសម្តែងទាំងពីរ(តួប្រុសនិងតួស្រី) គឺមានការកែច្នៃទៅជាទម្រង់ក្បាច់ផ្សេងៗជាច្រើនតាមធនធានរបស់ក្រុមល្ខោននីមួយៗ។

**ឃ- ណា**

ណា គឺជាមានលក្ខណៈខុសពីក្បាំង ស្វ៉ាងក និងប៉ាន់ដៃឫផាប់ដៃបន្តិច ពីព្រោះណាមិនមែនជាប្រភេទគ្រឿងអលង្ការសម្រាប់តុបតែងលម្អផ្នែកខាងលើរបស់តួឯកទេ ផ្ទុយទៅវិញ ណា គឺហាក់បីដូចជាផ្នែកមួយនៃសម្លៀកបំពាក់ ដែលគេប្រើសម្រាប់តែរុំប៉ែកខាងក្រោមរបស់តួឯកប្រុសប៉ុណ្ណោះ តែមិនមានលក្ខណៈបិទជិតទាំងស្រុងទេ គឺមានលក្ខណៈជាបន្ទះៗ ដែលជួនកាលមានចំនួនជាបីបន្ទះ(មួយបន្ទះសម្រាប់បាំងខាងមុខនិងពីរបន្ទះសម្រាប់បាំងចំហៀងត្រគៀក) ជួនកាលមានចំនួនបួនបន្ទះ(មួយបន្ទះសម្រាប់បាំងខាងមុខ ហើយពីរបន្ទះសម្រាប់បាំងចំហៀងត្រគៀកនិងមួយបន្ទះទៀតសម្រាប់បាំងខាងក្រោយ) តាមការនិយមរបស់ក្រុមល្ខោន។

គេធ្វើណាពីក្រណាត់មានប៉ាក់ឌិនចម្រុះពណ៌ មានក្បាច់ច្រើនតាមចំណង់ចំណូលចិត្តរបស់អ្នកធ្វើនិងអ្នកពាក់។ ផ្នែកខាងមុខមានចំនួនពី២ទៅ៣ស្រទាប់ ដែលស្រទាប់នីមួយៗមានរាងដូចជាស្រទាប់ផ្កាឈូក ហើយបន្ទះរបស់វាធំជាងផ្នែកចំហៀង និងផ្នែកខាងក្រោយ ព្រមទាំងមានរចនានូវម៉ូតប្លែកៗស្រស់ស្អាតជាងទៀតផង។ មូលហេតុដែលគេធ្វើបន្ទះខាងមុខមានច្រើនស្រទាប់ និងរចនាម៉ូតច្រើនបែបនេះដោយសារគេយល់ថា ពេលសម្តែងអ្នកទស្សនាមើលចំពីមុខច្រើនជាង។



ម៉ូតផ្សេងៗរបស់ណាផ្ទាំងខាងមុខ


ណាតួប្រុសចំហៀងខាងស្តាំ


ណាតួប្រុសចំហៀងខាងឆ្វេង

តួប្រុសប្រើណា ដើម្បីបិទបាំងនូវចំណុចកេរ្តិ៍ខ្មាសរបស់ខ្លួនក៏ដូចជាការពារក្នុងករណីខោរហែក ដើម្បីកុំឱ្យគេឃើញ ព្រោះសាច់រឿងនៅក្នុងល្ខោនបាសាក់ភាគច្រើនតួសម្តែងត្រូវធ្វើសឹកសង្គ្រាម វាយប្រយុទ្ធជាមួយយក្ស ឬខ្មាំងសត្រូវច្រើន ម្យ៉ាងទៀតពាក់ណា ក៏ដូចជាការតុបតែងនូវម៉ូតខោដើម្បីទាក់ទាញអ្នកទស្សនា និងធ្វើឱ្យមានសោភ័ណភាពទ្វេរឡើងសម្រាប់តួសម្តែងប្រុស។ ចំណែកតួស្រីពុំប្រើណានោះទេ ព្រោះតួស្រីស្លៀកសំពត់វែងដែលអាចបិទបាំងរាងកាយបានល្អស្រាប់ទៅហើយ។

ដូច្នេះ យើងឃើញថា នៅក្នុងល្ខោនបាសាក់ ក្បាំង សូវ៉ែក ប៉ាន់ដៃឬផាប់ដៃ និងណា គឺសុទ្ធតែជាគ្រឿងលម្អដ៏ចាំបាច់បំផុតដែលគេត្រូវយកមកប្រើដើម្បីតុបតែងលម្អតួសម្តែង ជាពិសេសម្រាប់តួឯក គ្រាន់តែគ្រឿងខ្លះគេអាចប្រើទាំងតួប្រុសនិងតួស្រី តែគ្រឿងខ្លះប្រើសម្រាប់តែតួប្រុសប៉ុណ្ណោះ។ គ្រឿងសម្រាប់តួប្រុស និងតួស្រីមានទម្រង់និងលក្ខណៈខុសគ្នា។ ចំពោះមូលហេតុដែលតួឯក( ទាំងតួប្រុសនិងតួស្រី ) នៃល្ខោនបាសាក់ចាំបាច់ត្រូវពាក់គ្រឿងតុបតែងលម្អទាំងនោះ គឺដោយសារៈ[8]

- គេចង់រំលេចថា តួសម្តែងទាំងពីរនេះ គឺជាតួដែលមានឋានៈខ្ពង់ខ្ពស់ មានមហិទ្ធិរិទ្ធិ អំណាច និងកេរ្តិ៍ឈ្មោះលើសគេក្នុងអាណាចក្រឬដែនដី
- តួសម្តែងទាំងពីរ គឺជាមនុស្សដែលកើតក្នុងត្រកូលក្សត្រ សេដ្ឋី ឬសេនាបតីធំៗ
- បង្ហាញពីភាពលេចធ្លោរបស់តួសម្តែងទាំងពីរ គឺជាមនុស្សដែលពុំមាននរណាប្រៀបស្មើបានទាំងសម្រស់ អំណាច មហិទ្ធិរិទ្ធិ និងទ្រព្យសម្បត្តិ
- និងចំណុចសំខាន់គឺដើម្បីលើកសោភ័ណភាពនៃសាច់រឿង។

[8] គយ សារ៉ុម : ការសម្ភាសអំពី«គ្រឿងលម្អតួនៅក្នុងល្ខោនបាសាក់ខ្មែរ», ដ. ឯ. ម

## ៤- សន្និដ្ឋាន

ជារួមយើងឃើញថាល្ខោនបាសាក់ គឺជាល្ខោនរបស់ខ្មែរមួយប្រភេទដែលមានមិនមានឬសគល់ដោយផ្ទាល់នៅក្នុងប្រទេសកម្ពុជាយើងឡើយ ពោលគឺជាល្ខោនដែលមានការចម្លងពីប្រទេសដទៃ គ្រាន់តែបុព្វបុរសនិងអ្នកជំនាញខាងសិល្បៈរបស់យើងព្យាយាមក្នុងការច្នៃប្រឌិតឱ្យអ្វីៗមកជាទម្រង់ខ្មែរ តាមរយៈសាច់រឿង និងពណ៌សម្បុររបស់តួសម្ដែងនិងគ្រឿងតុបតែងលម្អមួយចំនួន ដើម្បីកុំឱ្យឃើញថាខ្មែរយើងចម្លងពីគេទាំងស្រុងពេក ពោលគឺបុព្វបុរសយើងខិតខំធ្វើឱ្យមានលក្ខណៈជាខ្មែរនិងមានភាពរស់រវើក។

ជាក់ស្ដែង សូម្បីការប្រើប្រាស់គ្រឿងតុបតែងលម្អតួសម្ដែងនៅល្ខោននេះ គឺមានគិតពិចារណាយ៉ាងហ្មត់ចត់ពីខ្លឹមសារ អត្ថរស និងអត្ថន័យមុននឹងឱ្យតួសម្ដែងប្រើ ជាពិសេសទាក់ទងទៅនឹងគុណតម្លៃ និងសោភ័ណភាព។ លើសពីនេះទៅទៀត អ្វីដែលយើងបានឃើញ គឺក្បាំង សូរ៉ងក ប៉ាន់ដៃឬផាប់ដៃ ក៏ដូចជាណា គឺសុទ្ធតែជាគ្រឿងតុបតែងដែលចាំបាច់សម្រាប់ល្ខោននេះដោយមិនអាចខ្វះបាន ហើយគ្រឿងតុបតែងទាំងនេះ មិនមែនចេះតែនឹកឃើញបង្កើតវាឡើងនោះទេ គឺវាមានប្រភព និងមូលហេតុច្បាស់លាស់ក្នុងការយកមកប្រើប្រាស់។ គ្រាន់តែពេលខ្លះវាមានការវិវត្ត និងកែច្នៃទៅតាមពេលវេលាដើម្បីចងចិត្តចងអារម្មណ៍របស់មហាជនកុំឱ្យមានការធុញទ្រាន់ក្នុងការទស្សនា និងដើម្បីធ្វើឱ្យសិល្បៈល្ខោនបាសាក់កាន់តែមានភាពសម្បូរបែបនៅក្នុងសម័យពហុវប្បធម៌។

ប៉ុន្តែអ្វីដែលយើងគួរតែចងចាំ និងគិតពិចារណា គឺថា តើគួរធ្វើដូចម្ដេចដើម្បីកុំឱ្យគ្រឿងតុបតែងលម្អទាំងនោះឃ្លាតឆ្ងាយពីល្ខោនប្រភេទនេះ ហើយធ្វើដូចម្ដេចដើម្បីឱ្យប្រជាជនខ្មែរទាំងអស់បានយល់ពីខ្លឹមសារ និងអត្ថរសនៃការប្រើគ្រឿងទាំងនេះ ព្រមទាំងពីប្រភពរបស់វា ព្រោះយោងតាមការស្រាវជ្រាវ និងសម្ភាសន៍កន្លងមកមានទស្សនិកជន(ប្រជាពលរដ្ឋ)ជាច្រើនពុំមានការយល់ដឹងនិងចាប់អារម្មណ៍ពីប្រភពពីមូលហេតុ និងពីការប្រើប្រាស់គ្រឿងទាំងនោះ។ ក្នុងនោះ សូម្បីសិល្បករមួយចំនួនដែលសម្ដែងល្ខោននេះក៏ពុំបានដឹងដែរ នេះបញ្ជាក់ឱ្យឃើញថា ការដែលគេមិនចាប់អារម្មណ៍លើគ្រឿងតុបតែងលម្អរបស់តួសម្ដែងនៃល្ខោនបាសាក់ គឺមានន័យថាពួកគេក៏មិនចាប់អារម្មណ៍លើល្ខោននេះដែរ ដែលយើងអាចនិយាយបានថាល្ខោនបាសាក់បានបាត់បង់ទាំងស្រុងនៅក្នុងចំណោមប្រជាជនជនកម្ពុជាជំនាន់ក្រោយនេះ។

ដូច្នេះ អ្វីដែលជាចម្បងចំពោះមុខ ដើម្បីលើកស្ទួយល្ខោនបាសាក់ឡើងវិញ គឺត្រូវរួមគ្នាផ្សព្វផ្សាយនិងលើកតម្កើងល្ខោននេះទៅក្នុងស្រទាប់ប្រជាជនខ្មែរឡើងវិញ។

# ឯកសារពិគ្រោះ


១- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, របាំក្បាច់បុរាណខ្មែរ, គណៈកម្មការស្រាវជ្រាវរបាំក្បាច់បុរាណខ្មែរ, ភ្នំពេញ, ២០០៧

២- គណៈកម្មការស្រាវជ្រាវវប្បធម៌សិល្បៈ ទស្សនីយភាពខ្មែរ, រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា, ភ្នំពេញ, ២០០៣

៣- គយ សារ៉ុម, ការសម្ភាសន៍ផ្ទាល់, តាកែវ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១

៤- យីង ហុកឌី, រស្មីកម្មអក្សរសិល្ប៍ចិនលើកម្ពុជានាសតវត្សទី១៩ និងទី២០, បណ្ណាគារអង្គរ, ភ្នំពេញ, ២០០៨

៥- ឆេង ផុន និងពេជ្រ ទុំក្រវិល, តន្ត្រី របាំ និងល្ខោនខ្មែរ, ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ, ២០០៦

៦- ប្រាក់ ប៊ិន, ការសម្ភាសន៍ផ្ទាល់, មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០១១

៧- ពេជ្រ ទុំក្រវិល, តន្ត្រី របាំ និងល្ខោនខ្មែរ, គ្រឹះស្ថានបោះពុម្ពផ្សាយសាស្ត្រា, រោងពុម្ពពន្លឺខ្មែរ, ភ្នំពេញ, ២០១០

៨- ម៉ៅ កេង, ការសម្ភាសន៍ផ្ទាល់, នាយកដ្ឋានសិល្បៈទស្សនីយភាពនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ភ្នំពេញ, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១

៩- សំរាំង កំសាន្ត, អ៊ុន ទឹម, ស៊ីក ប៊ុនហុក, គោលទស្សនៈធំៗចំពោះវប្បធម៌ខ្មែរ និងការអភិវឌ្ឍន៍, មជ្ឈមណ្ឌលវប្បធម៌ និងវិបស្សនា, កណ្ដាល, ២០០០

១០- www. khmerguide.com, Lakhaon Bassac ( Bassac Theatre )